**មាត្រា ៤ ._**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តពោធិសាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

# អនុក្រឹត្យ លេខ ១០ អនក្រ.បក

## ស្តីពី

## ការលុបឡូតិ៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងឡូតិ៍នេសាទ ខេត្តសៀមរាប ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទ ជាលក្ខណៈគ្រួសារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

Compiled by EWMI-Cambodia
"Safeguarding Cambodians' Land Rights Project"
supported by US Department of State (04/09)

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃ ទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- **យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

## សំរេច

**មាត្រា ១ .-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់ នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាប ក្នុងខេត្តសៀមរាប ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទបឹងព្រែក លេខ ១. ២. ៣ និងលេខ ៥ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទ នៃផ្ទៃដែននេសាទក្នុងខេត្តសៀមរាប និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តសៀមរាប ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា ( ហិកតា)

| ប្រភេទ និងលេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| **បឹងព្រែក** | | | | | |
| ១ | ៦ ៩៧៣ | ៦ ៩៧៣ | ០ | ១០០ | លុបចេញ |
| ២ | ៥ ១៣៤ | ៥ ១៣៤ | ០ | ១០០ | លុបចេញ |
| ៣ | ៧ ៨៨០ | ៧ ៨៨០ | ០ | ១០០ | លុបចេញ |

| | | | | | |
|---|---|---|---|---|---|
| ៤ | ៤ ៨០៨ | ២ ៤៨៣ | ២ ៣២៥ | ៥១ ៦៤ | |
| ៥ | ៨ ៤៨៣ | ៨ ៤៨៣ | ០ | ១០០ | លុបចោល |
| ៦ | ៣១ ២៣២ | ១៩ ២៨៣ | ១១ ៩៤៩ | ៦១ .៧៤ | |
| ៧ | ១៩ ៤៣១ | ១០ ៩៨០ | ៨ ៤៥១ | ៥៦ .៥០ | |
| សរុប ៧ | ៨៣ ៩៤១ | ៦១ ២១៦ | ២២ ៧២៥ | ៧២ .៩២ | |

**មាត្រា ២ .-**

ដែននេសាទដែលបានលុបចោល និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូន ប្រជាពលរដ្ឋប្រកបរបរ នេសាទគ្រួសារ ហាមដាច់ខាតមិនអោយជនណាមួយហ៊ុំព័ទ្ធយកទៅលក់ ឬ ជួលអោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ នេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ.ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)